

# ជំរឿនប្រជាជន

CALIFORNIA ALL

2020

## ការធ្វើជំរឿនប្រជាជន គឺ កំពុងរៀបចំឡើងនៅក្នុងឆ្នាំ2020

ជំរឿនបន្ទាប់នឹងប្រព្រឹត្តទៅនៅរដូវផ្ការីក ឆ្នាំ2020។ សូមធានាថា ពលរដ្ឋកាលីហ្វ័រញ៉ាទាំងអស់ ត្រូវបានគេរាប់ចំនួន ដូចនេះយើងអាចដាក់ធនធានទាំងនោះសម្រាប់ការប្រើប្រាស់ឲ្យបានត្រឹមត្រូវនៅទីនេះ នៅរដ្ឋរបស់យើង!

- សាងសង់ផ្លូវថ្នល់ និងសាលារៀនឲ្យបានល្អប្រសើរ
- ផ្តល់មូលនិធិដល់កម្មវិធីសហគមន៍សម្រាប់មនុស្សចាស់ កុមារ និងក្រុមគ្រួសារនានា
- បង្កើតការងារធ្វើ
- កែលំអលំនៅដ្ឋាន

ចាប់ផ្តើមពីពាក់កណ្តាលខែមីនា ឆ្នាំ2020 គ្រួសារនីមួយៗនឹងទទួលបានលិខិតមួយច្បាប់តាមប្រៃសណីយ៍។ លិខិតនោះពន្យល់ពីរបៀបខុសៗគ្នាដែលអ្នកអាចបំពេញបែបបទជំរឿននោះបាន។ ប្រសិនបើអ្នកពុំទទួលបានលិខិតណាមួយទេ អ្នកនៅបន្តអាចចូលទៅកាន់ប្រព័ន្ធអនឡាញ ឬទូរសព្ទដើម្បីធ្វើការបំពេញវាបាន។ ត្រូវប្រាកដថា អ្នករាប់បញ្ចូលនូវបុគ្គលណាម្នាក់ដែលកំពុងរស់នៅក្នុងគ្រួសាររបស់អ្នក ទោះបីជាសមាជិកគ្រួសារឬមិនមែនក៏ដោយ។

## កាលបរិច្ឆេទធ្វើជំរឿនសំខាន់ៗ

| | |
|---|---|
| ថ្ងៃទី12 ខែមីនា ឆ្នាំ2020 | លិខិតអញ្ជើញសម្រាប់ជំរឿនឆ្នាំ2020 នឹងត្រូវបានផ្ញើតាមសំបុត្រប្រៃសណីយ៍ |
| ថ្ងៃទី16 ខែមីនា ឆ្នាំ2024 | លិខិតក្រើនរំឭក ត្រូវប្រគល់ជូនតាមប្រៃសណីយ៍ |
| ថ្ងៃទី26ខែមីនា-ថ្ងៃទី3ខែមេសា | កាតប៉ុស្តាល់ក្រើនរំឭក ត្រូវប្រគល់ជូនតាមប្រៃសណីយ៍ |
| ថ្ងៃទី1 ខែមេសា | ថ្ងៃធ្វើជំរឿន! |
| ថ្ងៃទី8 -16 ខែមេសា | លិខិតក្រើនរំឭកលើកទីពីរ និងឯកសារជំរឿនជាហាដកូពី នឹងត្រូវប្រគល់ជូនតាមប្រៃសណីយ៍ |
| ថ្ងៃទី20-27 ខែមេសា | កាត់ប៉ុស្តាល់ចុងក្រោយ ត្រូវប្រគល់ជូនមុនពេលចុះធ្វើការតាមដានដោយផ្ទាល់ |

## វិធីបីយ៉ាងដើម្បីបំពេញការធ្វើជំរឿននេះ

**តាមប្រៃសណីយ៍៖** ស្នើសុំក្រដាសទម្រង់បែបបទធ្វើជំរឿនជាភាសាអង់គ្លេស ឬភាសាអេស្ប៉ាញតាមប្រៃសណីយ៍ ដែលអាចផ្ញើត្រឡប់ទៅកាន់ក្រសួងជំរឿនប្រជាជនវិញបានតាមប្រៃសណីយ៍។

**តាមទូរសព្ទ៖** ជំរឿនអាចបំពេញបានតាមទូរសព្ទជា 13 ភាសា។

**តាមអិនធណិត៖** ជាលើកទីមួយហើយដែលបែបបទជំរឿននឹងអាចស្វែងរកមកបំពេញនៅតាមអិនធណិតជា 13 ភាសា។

ទិន្នន័យជំរឿនឆ្នាំ2020របស់អ្នក មានសុវត្ថិភាព ទទួលបានការការពារ និង មានលក្ខណៈសម្ងាត់។ រដ្ឋកាលីហ្វ័រញ៉ា បានប្តេជ្ញាចិត្ត ដើម្បីធានានូវការរាប់ចំនួនពលរដ្ឋកាលីហ្វ័រញ៉ាទាំងអស់ឲ្យបានពេញលេញនិងត្រឹមត្រូវនៅថ្ងៃទី1 ខែមេសា ឆ្នាំ2020។

CaliforniaCensus.org @CACensus